គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)

Committee For Free And Fair Elections In Cambodia (COMFREL)

ខុមហ្វ្រែល COMFREL

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

គណៈកម្មាធិការនាយក

BOARD OF DIRECTORS

លោក **ធន សារាយ**
Mr. THUN SARAY
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន ADHOC

លោក **សុក សំអឿន**
Mr. SOK Sam Oeun
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក CDP

លោក **យឹម ប៉ូ**
Mr. YIM Po អគ្គលេខាធិការ
និង នាយក CCPCR

កញ្ញា **ស៊ុន ចាន់សែន**
Miss. SUN Chansen
ប្រធាន KYA

លោក **មុំ សារិន**
Mr. MOM Sarin
នាយក HRCDO

លោកស្រី **ពឹង យក់ហៀប**
Mr. PEUNG Yok Hiep
នាយិកា LAC

លោកស្រី **ទីវ សារាយេត**
Ms. TIV Sarayet
សហនាយិកា WMC

កញ្ញា **សយ សារ៉ា វឌ្ឍនី**
Miss. SAY Sara Vathany
នាយិកា CWCC

លោក **គីម សុវណ្ណ**
Mr. KIM Sovann
នាយក VIGILANCE

លោក **អាង ច័ន្ទឫទ្ធិ**
Mr. ANG Chanrith
នាយក KKKHRO

លោក **យង់ គិមអេង**
Mr. YONG Kim Eng
នាយក PDP-Center

លោក **ភួង សិទ្ធិ**
Mr. PHUONG Sith

លោក **សឺន សែត**
Mr. SEN Set

ស.ប្រ.ក.៣/លេខ ១៨/០៩ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍[១] នៃវិស័យអាទិភាពក្នុង ខេត្ត ព្រៃវែង

*ភ្នំពេញ, ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩*

ប្រជាពលរដ្ឋប្រមាណ ១០០នាក់ មកពីស្រុកនានា និងក្រុងព្រៃវែងក្នុងខេត្តព្រៃវែង និងមានសិក្ខាកាមស្ត្រីចូលរួមប្រមាណ ២៧% បានជួបជុំគ្នានៅក្នុងសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តព្រៃវែងដើម្បីពិភាក្សា និងកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តព្រៃវែងកាលពីថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០០៩។

សិក្ខាសាលានេះក៏មានការចូលរួមពីអាជ្ញាធរខេត្ត និងតំណាងរាស្ត្រក្នុងមណ្ឌលព្រៃវែង ឯកឧត្តម **មីន ស៊ាន** ឯកឧត្តម **គង់ បូរ៉ា** និង ឯកឧត្តម **សៅ រ៉ានី** ផងដែរ ។

អភិបាលរងខេត្តព្រៃវែង លោក **ថង គឿន** បានមានប្រសាសន៍ដើម្បីបើកសិក្ខាសាលាថា រាជរដ្ឋាភិបាលនីតិកាលទី ៤ បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជាដំណាក់កាលទី ២ ។ សិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តព្រៃវែង គឺជាការរួមចំណែករបស់សង្គម ស៊ីវិលតាមវិធីមួយបែបទៀតដើម្បីផ្សារភ្ជាប់ពីតម្រូវការរបស់ប្រជាពលរដ្ឋក្នុងមណ្ឌលព្រៃវែងទៅឱ្យមន្ត្រីជាប់ឆ្នោត។

លោក **គល់ បញ្ញា** នាយកប្រតិបត្តិគណៈកម្មាធិការខុមហ្វ្រែលបានលើកឡើងថា សិក្ខាសាលានេះជាផ្នែកមួយរបស់លទ្ធិប្រជាធិបតេយ្យ គឺការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការកំណត់សេចក្តីត្រូវការដល់អង្គនីតិបញ្ញត្តិ និងនីតិប្រតិបត្តិ ខិតខំអនុវត្តកម្មវិធីនយោបាយរបស់ខ្លួនដែលបានសន្យាមុនពេលបោះឆ្នោត និងក្រោយពេលបោះឆ្នោត បន្ទាប់មក ប្រជាពលរដ្ឋចូលរួមសង្កេតថា តើមន្ត្រីជាប់ឆ្នោតអនុវត្តដល់ណាហើយ ។

---

[១] ការសន្យាណាដែលមានសូចនាករច្បាស់លាស់-អាចមានជាក់ស្តែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើតស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាស់លាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់។

អ្នកតំណាងរាស្ត្រដែលបានទទួលយក លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពដែលប្រជាពលរដ្ឋបានលើកឡើង បានមានប្រសាសន៍ថា ទាំងនេះគឺជាតួនាទីរបស់តំណាងរាស្ត្រ និងសភា ដើម្បីជំរុញទៅរាជរដ្ឋាភិបាល ។

អ្នកតំណាងរាស្ត្រ **មឹន ស៊ាន** បានមានប្រសាសន៍ថា *"អ្វីដែលធ្វើថ្ងៃនេះវាជាការមានប្រយោជន៍ ព្រោះសរុបមកគឺត្រូវដាក់ក្នុងតួនាទីតំណាងរាស្ត្រ និង របស់សភា"* ។

អ្នកតំណាងរាស្ត្រ **គង់ បូរ៉ា** បានលើកឡើងថា នេះជាការផ្តួចផ្តើមសំរាប់តំណាងរាស្ត្រ និងម្ចាស់ឆ្នោតបានជួបគ្នាដើម្បីប្រគល់ និងទទួលយកសំណូមពរពីប្រជាពលរដ្ឋដែលជាកម្ពល់នៅក្នុងខេត្ត *"ក្នុងនាមខ្ញុំជាតំណាងរាស្ត្រ វិស័យអាទិភាពទាំង ១០ នេះដែលសុទ្ធតែចាំបាច់ និងមានសារៈសំខាន់,.....ខ្ញុំនឹងប្រឹងដើម្បីអនុវត្ត និងទទួកយកសំណូមពរយកទៅពិចារណា ដើម្បីជួយអោយប្រទេសជាតិមានការរីកចំរើន,... "* ។

អ្នកតំណាងរាស្ត្រ **សៅ រ៉ានី** បានថ្លែងថា *"ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា វិស័យអាទិភាពទាំងនេះ តំណាងរាស្ត្រគ្រប់គណបក្ស...ជួយជំរុញអោយរដ្ឋាភិបាលបន្តការយកចិត្តទុកដាក់បន្ថែមទៀត,...* ។

លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង១០ ដែលបានកំណត់ដោយម្ចាស់ឆ្នោតក្នុងខេត្តព្រៃវែងរួមមានៈ

| **លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង១០នៅក្នុងខេត្ត ព្រៃវែង** |
|---|
| ១) សុំកាត់បន្ថយរាល់បទល្មើសសង្គម ដូចជា ឆក់ប្លន់ ល្បែងស៊ីសង ក្រុមក្មេងទំនើង គ្រឿងញៀន ជួញដូរកុមារ បានរំលោភកុមារ និងបទល្មើសនេសាទឆក់ត្រី អោយបាន ៧០% នៃឆ្នាំ ២០០៩ នៅទូទាំងខេត្តព្រៃវែង ដោយចាប់ផ្តើមក្នុងឆ្នាំ២០០៩ តទៅ។ |
| ២) សុំឱ្យក្រសួងពាណិជ្ជកម្ម និងក្រសួងកសិកម្ម ជួយរកទីផ្សារសហគមន៍ ដើម្បីលក់ផលិតផលស្រូវ ពោត សណ្តែក ល្ង ចំនួន ៦កន្លែង សំរាប់ប្រជាពលរដ្ឋនៅក្នុងស្រុកស៊ីធរកណ្តាល ស្រុកពាមរ ស្រុកបាភ្នំ ស្រុកកំពង់ត្របែក ស្រុកស្វាយអន្ទរ និង ក្រុងព្រៃវែង ឱ្យបាននៅក្នុងឆ្នាំ២០១១។ សុំឱ្យរាជរដ្ឋាភិបាលបន្ថយការយកពន្ធជីនាំចូលក្នុងប្រទេសទាបជាង ៥០% នៃតម្លៃបច្ចុប្បន្នចាប់ពីឆ្នាំ ២០១០ តទៅ។ និងសុំឱ្យមន្ទីរកសិកម្មជួយផ្តល់បច្ចេកទេសសមស្រប (ធ្វើជីកំប៉ុស និងដាំបន្លែ) ដល់ប្រជាពលរដ្ឋក្នុងខេត្តព្រៃវែង។ |
| ៣) សុំប្រធានមន្ទីរសុខាភិបាលខេត្តព្រៃវែង ជួយសំរួលដល់មន្ទីរពេទ្យបង្អែកព្រៃវែង និងអ្នកលឿង ដូចជាៈ<br>- សុំឱ្យគ្រូពេទ្យព្យាបាលសិនទើបយកប្រាក់ជាក្រោយពីអ្នកជំងឺ<br>- សុំឱ្យមានថ្នាំគ្រប់គ្រាន់សំរាប់ព្យាបាល<br>- សុំកាត់បន្ថយសេវាព្យាបាលឱ្យបាន ៥០% នៃថ្លៃសេវាបច្ចុប្បន្ន ចាប់ពីចុងឆ្នាំ២០០៩ តទៅ។ |
| ៤) សុំឱ្យក្រសួងកសិកម្មសហការជាមួយ អង្គការនានា ដើម្បីបង្កើតសហគមន៍ ចិញ្ចឹមសត្វ ដូចជា គោ ជ្រូក ត្រី មាន់... និងផ្តល់ពូជស្មៅ ចំណីសត្វដល់ [ សហគមន៍ ] នៅទូទាំងខេត្តព្រៃវែងឱ្យបាននៅក្នុងឆ្នាំ២០១០។ |
| ៥) សុំអោយមានការពន្លឿនការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយឱ្យបានត្រឹមឆ្នាំ២០១០។ |
| ៦) សុំឱ្យរាជរដ្ឋាភិបាលជួយជួសជុលផ្លូវកៅស៊ូ ប្រវែង ១០០ម ទទឹង ៨ម នៅភូមិលេខ៣ សង្កាត់កំពង់លាវ ខេត្តព្រៃវែង (ផ្លូវក្រោយវត្តសំសមី ចូលផ្សារ) ចាប់ផ្តើមពីដើមឆ្នាំ ២០១០ និងបញ្ចប់នៅឆ្នាំ២០១០។<br>- សុំជួសជុលផ្លូវគ្រួសក្រហម ប្រវែង ១៣គម ពីចំណុចភូមិពានា ឃុំអំពិលក្រៅ ដល់ភូមិដើមថ្នឹង ឃុំព្រៃដើមថ្នឹង ស្រុកស៊ីធរកណ្តាល ចាប់ពីឆ្នាំ២០១០ បញ្ចប់ ១០០% ក្នុងឆ្នាំ២០១១។ |

| |
|---|
| - សុំជួសជុលផ្លូវគ្រួសក្រហម ប្រវែង ១៨០០ម ពីផ្លូវជាតិលេខ ១១ ក្នុងភូមិ និគមព្រះសុរាម្រឹតសីហនុ ឃុំបាបោង ស្រុកពាមរ ខេត្តព្រៃវែង ចាប់ពីឆ្នាំ២០១០ បញ្ចប់ ១០០% ក្នុងឆ្នាំ២០១១។ |
| ៧) សុំរាជរដ្ឋាភិបាលជួយបង្កើតរោងចក្រកាត់ដេរឱ្យបានគ្រប់ស្រុក (មួយស្រុក មួយកន្លែង) នៅក្នុងខេត្តព្រៃវែង ឱ្យបានចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ ២០១២។ |
| ៨) សុំឱ្យអភិបាលនៃគណៈអភិបាលខេត្ត បំពាក់អំពូលភ្លើងគ្រប់ដងវិថីទាំងអស់ នៅក្នុងក្រុងព្រៃវែង ខេត្តព្រៃវែង ចាប់ពីដើមឆ្នាំ២០១០ បញ្ចប់ ក្នុងនៅចុងឆ្នាំ២០១០។ |
| ៩) ពេលបង្កើតរោងចក្របានហើយ សុំឱ្យរាជរដ្ឋាភិបាលជួយបង្កើនប្រាក់បៀវត្សរ៍ដល់កម្មកររោងចក្រ ឱ្យបានចំនួន ១០០ដុល្លារ ក្នុងមួយខែឡើងទៅ ចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១២។ |
| ១០) សុំតម្លើងប្រាក់បៀវត្សរ៍ដល់មន្ត្រីរាជការ (គ្រូបង្រៀន និងគ្រូពេទ្យ) អោយបានចាប់ពី ៤០ម៉ឺនរៀល ឡើងទៅ ចាប់ផ្តើមនៅខែ១១ ឆ្នាំ២០០៩ នេះតទៅ នៅទូទាំងខេត្តព្រៃវែង។ |

សិក្ខាសាលានេះត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការខុមហ្វ្រែល សហការជាមួយអង្គការសហការដើម្បីអភិវឌ្ឍន៍នៅកម្ពុជា (PADEK), សមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC), អង្គការពន្លឺនៃក្តីសង្ឃឹម (PNKS), , អង្គការអតីតយុទ្ធជនអន្តរជាតិ (VI), គណៈកម្មាធិការអព្យាក្រឹតដើម្បី ការបោះឆ្នោត ដោយសេរី និងយុត្តិធម៌នៅកម្ពុជា (NICFEC) ដែលក្នុងនោះមានការចូលរួមពីម្ចាស់ឆ្នោត ដែលតំណាងឱ្យសហគមន៍ អង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/ និស្សិត កសិករ មកពីស្រុកពាមរ ស្រុកស៊ីធរកណ្តាល ស្រុកមេសាង ស្រុកកំចាយមារ ស្រុកកញ្ជ្រៀច ស្រុកបាភ្នំ ស្រុកព្រះស្តេច ស្រុកពារាំង និងក្រុងកំពង់លាវ នៅក្នុងខេត្តព្រៃវែង។

សិក្ខាសាលាម្ចាស់ឆ្នោតនេះ ជាគំនិតបង្កើតថ្មីមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត នៅតាមមណ្ឌលនីមួយៗ:

១) មានការយល់ដឹងពីកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលជាប់ឆ្នោតឆ្នាំ ២០០៨

២) ចូលរួមក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានា ដែលត្រូវការចាំបាច់ក្នុងមណ្ឌល (ខេត្ត) របស់ខ្លួន

៣) និង លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានាសម្រាប់មណ្ឌលនីមួយៗ ត្រូវបានចងក្រងជារបាយការណ៍ ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តរបស់រាជរដ្ឋាភិបាល អ្នកតំណាងរាស្ត្រ ក្រុមប្រឹក្សា/គណៈអភិបាលខេត្ត-រាជធានី ក្នុងការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យទាំងនោះ។

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទង:*

- លោក **គឹម ឈន** អ្នកសម្របសម្រួលកម្មវិធីជាន់ខ្ពស់ខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៩៤២ ០១៩
- លោក **សុខ ពិន្ទុរឿ** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: ០៨៩ ៥២៥ ៤៤៦